## រោគសញ្ញា – ជម្ងឺម៉េនីញជោខូកខាល

បុគ្គលដែលបង្ហាញឲ្យឃើញរោគសញ្ញាជាដំបូងនៃជម្ងឺម៉េនីញជោខូកខាល ប្រហែលជាមិនបង្ហាញឲ្យឃើញគ្រប់ទាំងរោគសញ្ញានេះទេ ហើយរោគសញ្ញាទាំងនេះប្រហែលជាមិនបង្ហាញឲ្យឃើញក្នុងពេលតែមួយនោះឡើយ:

- ចាប់ផ្តើមគ្រុនភ្លាមៗ
- ឈឺក្បាលខ្លាំង
- ចេះតែងងុយដេក ច្រមូលច្របល់ ឬសន្លប់
- រោយក ឈឺក្នុងសន្លាក់ឆ្អឹង
- ស្នាមកន្ទួលពណ៌ក្រហមស្វាយដុំៗ ឬជាំ
- មិនចូលចិត្តពន្លឺចាំង
- ក្អួត

រោគសញ្ញាបន្ថែមដែលត្រូវឃ្លាំមើលក្នុង**ទារក**គឺ:

- ការខឹងសប្បារ
- ការយំថ្ងូរស្រែកខ្លាំង
- លំបាកភ្ញាក់ពីដំណេក
- មិនព្រមញ៉ាំ
- ស្បែកសម្បុរស្លេកស្លាំង ឬសម្បុរស្លាកស្នាម។

## ពត៌មានបន្ថែមទៀត

នឹងមានការខុសគ្នាបន្តិចបន្តួច នៅក្នុងលំនាំកម្មវិធីជាតិលើការចាក់ថ្នាំការពារជម្ងឺម៉េនីញជោខូកខាល ជំពូកសី ដែលត្រូវអនុវត្តសំរាប់ក្មេងអាយុពី៦ឆ្នាំ ទៅ១៩ឆ្នាំ នៅក្នុងរដ្ឋ និងដែនដីរបស់លោកអ្នក។ ចំពោះពត៌មានបន្ថែមទៀត លោកអ្នកគួរទាក់ទងជាមួយក្រសួងសុខាភិបាលប្រចាំរដ្ឋ ឬដែនដីរបស់លោកអ្នក។

## លេខទូរស័ព្ទទាក់ទងក្នុងរដ្ឋ/ដែនដី

| | |
|---|---|
| **ACT** | (02) 6205 2300 |
| **NSW** | Public Health Unit (ក្រុមសុខភាពសហគមន៍) (សូមមើលនៅក្រោមពាក្យ "Health" នៅក្នុងសៀវភៅទូរស័ព្ទពណ៌ស) |
| **NT** | (08) 8922 8044 |
| **Qld** | (07) 3234 1500 |
| **SA** | (08) 8226 7177 |
| **Tas** | (03) 6233 3762 or ឬ 1800 671 738 (សំរាប់តែ Tasmania ប៉ុណ្ណោះ) |
| **Vic** | (03) 9637 4144 |
| **WA** | (08) 9321 1312 |

ដើម្បីទទួលយកពត៌មានទូទៅបន្ថែមទៀតអំពីកម្មវិធីជាតិលើការចាក់ថ្នាំការពារជម្ងឺម៉េនីញជោខូកខាល ជំពូកសី សូមមើល Immunise Australia (ចាក់ថ្នាំបង្ការរោគ អូស្ត្រាលី) នៅត្រង់កន្លែង **www.immunise.health.gov.au** ឬទូរស័ព្ទទៅខ្សែរទូរស័ព្ទទាន់ចិត្តរបស់ Immunisation Infoline លេខ **1800 671 811**។

## លេខទូរស័ព្ទទាក់ទងដែលមានប្រយោជន៍

វេជ្ជបណ្ឌិតរបស់លោកអ្នក:

មន្ទីរពេទ្យប្រចាំតំបន់របស់លោកអ្នកផ្នែកភាពអាសន្ន:

នៅក្នុងភាពអាសន្ន សូមទូរស័ព្ទលេខ 000 (ឬលេខ 112 ចេញពីទូរស័ព្ទចល័ត)។

Khmer

Australian Government
Department of Health and Ageing

# កម្មវិធីជាតិលើការចាក់ថ្នាំការពារជម្ងឺម៉េនីញជោខូកខាល ជំពូកសី

## សំណួរ និងចម្លើយ

## ហេតុការណ៍ពិតនាំងឡាយសំរាប់មាតាបិតា

(កែសម្រួលទាន់ពេល ខែតុលា ឆ្នាំ២០០៣)

IMMUNISE AUSTRALIA PROGRAM

ការចាក់ថ្នាំបង្ការរោគ

## តើកម្មវិធីជាតិលើការចាក់ថ្នាំការពារជម្ងឺម៉េនីញ៉ូជោខូកខាល ជំពូកសី ជាអ្វី?

រយៈពេលបួនឆ្នាំខាងមុខ ដែលជាផ្នែកនៃការឆ្លើយតបដ៏ធំទូលាយរបស់រដ្ឋាភិបាលអូស្ត្រាលី ក្នុងការកាត់បន្ថយឥទ្ធិពលនៃជម្ងឺម៉េនីញ៉ូជោខូកខាល ជំពូកសី លើសហគមន៍ កម្មវិធីចាក់ថ្នាំការពារជម្ងឺម៉េនីញ៉ូជោខូកខាល ជំពូកសី នឹងផ្តល់ជូនការចាក់ថ្នាំការពារជម្ងឺម៉េនីញ៉ូជោខូកខាល ជំពូកសី ដោយឥតគិតថ្លៃសំរាប់កុមារ និងក្មេងជំទង់ដែលចូលអាយុ១ឆ្នាំ ទៅដល់១៩ឆ្នាំ នៅក្នុងឆ្នាំ២០០៣។ នេះគឺជាកម្មវិធីចាក់ថ្នាំបង្ការរោគមួយ ដែលគេឃើញធំជាងគេបំផុតនៅក្នុងប្រទេសអូស្តាលី។

## តើជម្ងឺម៉េនីញ៉ូជោខូកខាល ជាអ្វី?

វាគឺជាជម្ងឺមួយដែលគំរាមគំហែងដល់ជីវិត កើតខុសប្លែកពីធម្មតា បណ្តាលមកពីបាក់តេរីរស់នៅផ្នែកខាងក្រោយបំពង់ក ឬក្នុងច្រមុះនៅក្នុងចំណោមមនុស្សប្រហែលជា១០ភាគរយនៃសហគមន៍ ក្នុងពេលណាមួយ។ ថ្វីដ្បិតតែមនុស្សភាគច្រើនដែលមានបាក់តេរីទាំងនេះ នៅមានសុខភាពល្អជាយ៉ាងណាក្តី គេអាចចម្លងមេរោគនោះទៅដល់អ្នកដទៃទៀត ដែលក្នុងករណីខ្លះអ្នកឆ្លងជម្ងឺនេះអាចទៅជាឈឺយ៉ាងធ្ងន់ធ្ងរ។

ជម្ងឺម៉េនីញ៉ូជោខូកខាល អាចកើតមាននៅពេលណាមួយនៅក្នុងឆ្នាំក៏ប៉ុន្តែជាញឹកញយ វាតែងកើតមាននៅក្នុងរដូវត្រជាក់ និងរដូវផ្ការីក។ មានជំពូកនៃជម្ងឺម៉េនីញ៉ូជោខូកខាលខុសៗគ្នា ដែលមានជំពូកបី និងជំពូកសី ស្ទើងតែទូទៅនៅក្នុងប្រទេសអូស្ត្រាលី។ ជម្ងឺម៉េនីញ៉ូជោខូកខាល ជំពូកសី បង្ហាញហេតុផលថាមានមនុស្សច្រើនជាងពាក់កណ្តាលបានស្លាប់ដោយសារជម្ងឺនេះ នៅក្នុងប្រទេសអូស្ត្រាលី។

## ថ្នាំបង្ការរោគដែលប្រើនៅក្នុងកម្មវិធីជាតិលើការចាក់ថ្នាំការពារជម្ងឺម៉េនីញ៉ូជោខូកខាល ជំពូកសី សំរាប់ការពារទប់ទល់តែជម្ងឺម៉េនីញ៉ូជោខូកខាល ជំពូកសី ប៉ុណ្ណោះ។

មានជំពូកជម្ងឺម៉េនីញ៉ូជោខូកខាលដទៃទៀត (ឧទាហរណ៍ បណ្តាលមកពីជំពូកបី) ដែលមិនបានគ្របដណ្តប់ដោយថ្នាំចាក់ការពារនេះទេ។ នៅក្នុងពេលឥឡូវនេះ ឥតមានថ្នាំចាក់ការពារណាដែលមានប្រសិទ្ធិភាព ត្រូវបានរៀបចំឡើងសំរាប់ការពារជម្ងឺម៉េនីញ៉ូជោខូកខាល ជំពូកបី នៅក្នុងប្រទេសអូស្ត្រាលីទេ។

វាជាការសំខាន់ដែលត្រូវប្រុងប្រយ័ត្នឃ្លាំមើលរោគសញ្ញានៃជម្ងឺម៉េនីញ៉ូជោខូកខាល។ ប្រសិនបើឃើញកើតមានរោគសញ្ញាទាំងឡាយ សូមស្វែងរកជំនួយខាងផ្លូវពេទ្យជាបន្ទាន់។

## តើជម្ងឺនេះឆ្លងរាលដាលដោយបែបណា?

បាក់តេរីឆ្លងរាលដាលតាមតំណក់តូចៗដែលជ្រុះចេញពីច្រមុះ ឬបំពង់ក តាមរយៈការក្អក កណ្តាស់ និងការនិយាយញាប់។

## តើវាងាយឆ្លងរាលដាលយ៉ាងណាដែរ?

ថ្វីដ្បិតតែបាក់តេរីវាឆ្លងរាលដាលតាមរយៈដំណក់តូចៗជាយ៉ាងណាក្តី វាមិនងាយនឹងកើតមានជម្ងឺទេ។ មូលហេតុគឺដោយព្រោះតែបាក់តេរី មិនអាចរស់នៅបានយូរនៅខាងក្រៅរូបកាយឡើយ។

## តើនរណាដែលស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ជាងគេ?

ជម្ងឺម៉េនីញ៉ូជោខូកខាល អាចកើតមានឡើងនៅក្នុងវ័យណាមួយ។ ក្រុមដែលមានគ្រោះថ្នាក់ច្រើនជាងគេ គឺកុមារដែលមានអាយុនៅក្រោម៥ឆ្នាំ និង១៥ឆ្នាំ ទៅ១៩ឆ្នាំ។

## តើលោកអ្នកត្រូវធ្វើដូចម្តេច ប្រសិនបើឃើញរោគសញ្ញាកើតមានឡើង?

សូមទៅជួបវេជ្ជបណ្ឌិតរបស់លោកអ្នកភ្លាម ឬទៅមន្ទីរពេទ្យផ្នែកភាពអាសន្នដែលនៅជិតលោកអ្នកតែម្តង។

ការធ្វើរោគវិនិច្ឆ័យ មិនមែនជាការងាយស្រួលរាល់ពេលនៅគ្រាដំបូងឡើយ។ ដូច្នេះប្រសិនបើវេជ្ជបណ្ឌិត ឬមន្ទីពេទ្យបញ្ជូនបុគ្គលឲ្យត្រឡប់ទៅផ្ទះវិញ ហើយរោគសញ្ញាចេះតែកើតមានធ្ងន់ធ្ងរទៅ ឬមិនឃើញគ្រាន់បើទាល់តែសោះ សូមយកអ្នកជម្ងឺត្រឡប់ទៅមន្ទីរពេទ្យដែលនៅជិតលោកអ្នកវិញភ្លាម។

## តើគេព្យាបាលជម្ងឺនេះដោយបែបណា?

បុគ្គលដែលមានរោគសញ្ញា ត្រូវបានព្យាបាលនៅក្នុងមន្ទីរពេទ្យជាមួយថ្នាំផ្សះអង់ទីប៊ីយូទិក។ ការព្យាបាលជាមួយថ្នាំអង់ទីប៊ីយូទិកជាដំបូងទាន់ពេល គឺជាចំណុចសំខាន់ដើម្បីសង្គ្រោះជីវិតបុគ្គលណាម្នាក់។

## តើខ្ញុំអាចការពារកូនរបស់ខ្ញុំដោយបែបណា?

មានរបៀបប្រុងប្រយ័ត្នខ្លះៗ ដែលលោកអ្នកអាចចាប់យកការសាកល្បងមកប្រើ ហើយការពារជម្ងឺ ដើម្បីកុំឲ្យកើតមាននៅក្នុងកូនរបស់លោកអ្នក។

១. ចាក់ថ្នាំបង្ការជម្ងឺម៉េនីញ៉ូជោខូកខាល ជំពូកសី ឲ្យកូនរបស់លោកអ្នក ដោយហេតុថាថ្នាំចាក់ការពារនេះ ផ្តល់នូវការការពារជាង៩០ភាគរយ ទប់ទល់នឹងជម្ងឺម៉េនីញ៉ូជោខូកខាលជំពូកសី។

២. កូនក្មេងនៃមាតាបិតាដែលពិសាបារី អាចមានគ្រោះថ្នាក់ពីការកើតមានជម្ងឺម៉េនីញ៉ូជោខូកខាល ច្រើនជាងគេ។ ដើម្បីទទួលយកជំនួយលះបង់ការពិសាបារី សូមទូរស័ព្ទទៅ Quitline លេខ 131 848 និយាយទៅកាន់វេជ្ជបណ្ឌិត ឬឱសថការីរបស់លោកអ្នក ឬសូមបើកមើលនៅត្រង់គេហទំព័រ www.immunise.health.gov.au។

## តើថ្នាំចាក់ការពារមានផលវិបាកណាមួយឬទេ?

ថ្នាំចាក់ការពារជម្ងឺម៉េនីញ៉ូជោខូកខាល ជំពូកសី ឥតមានគ្រោះថ្នាក់ទាល់តែសោះ។ វាពុំមានបាក់តេរីរស់នៅក្នុងវាទេ ហើយក៏មិនអាចបណ្តាលឲ្យកើតមានជម្ងឺម៉េនីញ៉ូជោខូកខាល ដល់កូនរបស់លោកអ្នកឡើយ។ វាមានប្រតិកម្មរាយរងបន្តិចបន្តួច ដែលកូនរបស់លោកអ្នកអាចជួយប្រទះ។ ប្រតិកម្មរាយរងដែលកើតមានជាទូទៅគឺឈឺ ឡើងក្រហម ហើយហើមនៅត្រង់កន្លែងចាក់ថ្នាំ គ្រុនក្រហាយ មិនសូវឃ្លាន ហើយឈឺក្បាល។ ប្រតិកម្មរាយរងទាំងនេះកើតមានតែក្នុងរយៈពេលខ្លីប៉ុណ្ណោះ។ ចំណែកឯប្រតិកម្មរាយរងធ្ងន់ធ្ងរ មិនសូវឃើញកើតមានទេ។ គ្រប់ពេលវេលា លោកអ្នកត្រូវពិភាក្សាអំពីប្រតិកម្មរាយរងដែលអាចនឹងកើតមានឡើងជាមួយអ្នកផ្តល់ការចាក់ថ្នាំការពារ មុននឹងចាក់ថ្នាំបង្ការរោគ។